ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងសិក្ខាសាលាស្តីពី គោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម "លើកកំពស់បរិស្ថានធុរៈកិច្ច ពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យម និងភាពប្រកួតប្រជែង" នៅសណ្ឋាគារ **Inter-Continental**






សិក្ខាសាលាស្តីពី គោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម**"លើកកំពស់បរិស្ថានធុរៈកិច្ច ពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យម និងភាពប្រកួតប្រជែង"** សហការរៀបចំដោយ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ប្រទេសជប៉ុន (JICA) ត្រូវបានប្រារព្ធធ្វើឡើង នាព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤

ក្រោមអធិបតីភាព ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោក **Hiroshi Izaki** ប្រធានតំណាងអង្គការ JICA ប្រចាំកម្ពុជា នៅសណ្ឋាគារ **Inter-Continental** រាជធានីភ្នំពេញ ។

គោលបំណងសំខាន់ នៃអង្គសិក្ខាសាលា គឺប្រកាសផ្សព្វផ្សាយអំពីការផ្តួចផ្តើមរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការរៀបចំគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម ជាលើកដំបូងនៅកម្ពុជា និងសូមប្រកាសស្វែងរក កិច្ចសហការ និងការសម្របសម្រួលនានាពី បណ្តាក្រសួងស្ថាប័ន ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍ជាតិ–អន្តរជាតិ ដើម្បីចូលរួមទាំងអស់គ្នា ក្នុងដំណើរការជម្រុញគោលនយោបាយនេះឱ្យដំណើរការទៅដោយរលូន ល្អប្រសើរ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។



លោកជំទាវ ពៅ **វរលក្ខណ៍** អគ្គនាយិកានៃអគ្គនាយកដ្ឋាន នៃសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអញ្ជើញមានប្រសាសន៍ស្វាគមន៍ និងរាយការណ៍ជូន ស្តីពីវឌ្ឍនភាពនៃដំណើរការគម្រោង ដោយបានបញ្ជាក់ថា៖ បច្ចុប្បន្ន តាមរយៈអង្គការ JICA ជប៉ុនបានកំពុងសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើគម្រោងពង្រឹងជាយុទ្ធសាស្ត្រដល់ប្រព័ន្ធគាំទ្រសហគ្រាសធុនតូច និងមធ្យម (**JICA Project for Strategic Strenthening of SME Support System**) មានរយៈពេល០២ ឆ្នាំ ដោយអនុវត្តចាប់ពីខែ មិថុនា ឆ្នាំ២០១៣ ដល់ខែឧសភា ឆ្នាំ២០១៥ ដែលត្រូវអនុវត្តទៅលើខេត្តក្រុង គោលដៅដូចជា៖ភ្នំពេញ ពោធិ៍សាត់ បាត់ដំបង កំពង់ចាម និងសៀមរាប ។ ក្នុងនោះជួយដល់អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដើម្បីរៀបចំគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូចនិងមធ្យម ដែលជាគោលនយោបាយលើកដំបូងនៅកម្ពុជា និង ជាមួយអគ្គនាយកដ្ឋានឧស្សាហកម្ម លើគម្រោងពង្រឹងសមត្ថភាពប្រឹក្សាយោបល់ ក្នុងការត្រួតពិនិត្យ វិភាគ ក្រុមហ៊ុនសហគ្រាស ដែលអនុវត្តដោយមជ្ឈមណ្ឌលផលិតភាពជាតិ (NPCC) ។

ចាប់តាំងពីគម្រោងនេះបានអនុវត្ត អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម បានសហការជាមួយ អង្គការ JICA ដោយបានរៀបចំសេចក្តីព្រាងទស្សនៈទាន **(Concept Notes)** សម្រាប់ជាទិសដៅនៃការអនុវត្ត និងបាន រៀបចំកិច្ចប្រជុំបឋមគណៈកម្មាធិការសម្របសម្រួលចម្រុះ **(Joint Coordinating Committee)** កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៤ នៅទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីស្នើសុំការចូលរួម និងសហការពីបណ្តាក្រសួង ស្ថាប័ន ពាក់ព័ន្ធ ក៏ដូចជាការផ្តល់អនុសាសន៍នានា ។ ជាក់ស្តែង តាមរយៈការសហការពីក្រសួង ស្ថាប័ន និងផ្នែកឯកជន យើងបានសម្រេចបង្កើតគណៈកម្មាធិការសម្របសម្រួលចម្រុះ (JCC) ដែលមានសមាជិកចំនួន២០រូប ដែលមានឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាប្រធាន កាលពីថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០១៤ ដែលគណៈកម្មាធិការនេះ នឹងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគម្រោងនេះ ។ ក្នុងនោះក៏មានបង្ហាញអំពីលទ្ធផលនៃការអង្កេតដោយ CDRI ទៅលើសហគ្រាសអាជីវកម្មចំនួនប្រមាណ ៣០០ ដើម្បីដឹងអំពីបញ្ហាប្រឈម និងសំណូមពរនានា និងមានក្រុមហ៊ុន សហគ្រាសចំនួន១២ ដែលកំពុងទទួលបានសេវាកម្មប្រឹក្សាយោបល់ ក្នុងការត្រួតពិនិត្យវិភាគស្វែងរកបញ្ហា ដែលកើតមាន ក្នុងសហគ្រាសរបស់ខ្លួន ។



លោក **IZAKI Hiroshi** ប្រធានតំណាងអង្គការ JICA ប្រចាំកម្ពុជា បានមានប្រសាសន៍ថា: យើងបានចាត់ទុកថា វិស័យ SME មានតួនាទីសំខាន់ណាស់សម្រាប់កំនើនសេដ្ឋកិច្ចនៅកម្ពុជា និងការកាត់បន្ថយភាពក្រីក្រ ។ អង្គការ JICA បាន គាំទ្រគោលនយោបាយលើកទឹកចិត្ត SME តាមរយៈការពង្រឹងប្រព័ន្ធគាំទ្រ SME នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចាប់ តាំងពីខែមិថុនា ឆ្នាំមុន ។ ផែនការសកម្មភាព បានរាប់បញ្ចូល នូវជំនួយបច្ចេកទេស សម្រាប់បង្កើតគោលនយោបាយលើក ទឹកចិត្ត SME និងការអភិវឌ្ឍន៍សមត្ថភាព នៅក្នុងការវិភាគក្រុមហ៊ុន សហគ្រាស សម្រាប់ផ្តល់នូវការអភិវឌ្ឍន៍វិស័យ SME នៅកម្ពុជា ។


INTERCONTINENTAL
PHNOMPENH





មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា៖ តាមរយៈគម្រោងរៀបចំគោល នយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យម អនុវត្តដោយអគ្គនាយកដ្ឋានអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម គឺជាលើកដំបូងនិងមានសារៈសំខាន់ ដែលក្រសួងចាប់ផ្តើមអនុវត្តជាមួយអង្គការ JICA ហើយគឺជាពេលវេលាសមស្របមួយ ដែលរាជរដ្ឋាភិបាលកំពុងរៀបចំ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ដែលក្នុងនោះបានផ្តោតលើការពង្រីក និងទំនើបកម្ម នៃវិស័យ SME ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា៖ គោលបំណងសំខាន់នៃការរៀបចំគោលនយោបាយនេះ គឺដើម្បីស្វែងរកគន្លឹះសម្រាប់ជម្រុញការអភិវឌ្ឍន៍វិស័យ SME នេះឱ្យមាននិរន្តរភាព ដែលជាឆ្អឹងខ្នងនៃកំនើនសេដ្ឋកិច្ចជាតិ ជាពិសេសវិស័យ SME បានចូលរួមផ្តល់ការងារ និងកំណើនប្រាក់ចំណូលរបស់ប្រជាជន ដែលជាសូចនាករមួយ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ ក្នុងវិស័យ SME នៅកម្ពុជា ខានចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងសង្គម និងសេដ្ឋកិច្ច ។ ជាក់ស្តែងតាមរយៈទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ បានបង្ហាញថា៖ មានសហគ្រាសធុនតូច និងមធ្យម និងសេវាកម្មកំពុងដំណើរការអាជីវកម្ម នៅទូទាំងប្រទេសមានចំនួនជាង ៥០៥ពាន់មូលដ្ឋាន គឺស្មើ៩៩% ជាប្រភេទ SME (ដោយមិនទាន់រាប់បញ្ចូលសហគ្រាសកសិកម្មនៅឡើយទេ) ដោយបង្កើតការងារសរុបចំនួនជាង ១.៦៧លានកន្លែង គឺស្មើនិង៧០% និងបានចូលរួមចំណែកប្រមាណ៦០% នៃផលទុនជាតិសរុប ។ ដោយឡែកផ្នែកសហគ្រាសធុនតូច និងមធ្យម ផ្នែកកម្មនសាលនៅទូទាំងប្រទេសមានចំនួនជាង ៣៨ពាន់មូលដ្ឋាន បានចុះបញ្ជីដំណើរការអាជីវកម្មស្របច្បាប់ និងបានបង្កើតការងារសរុបចំនួនជាង១៨៦ពាន់កន្លែង ។ ការជ្រើសរើសដៃគូជាមួយ JICA ជាគន្លឹះយ៉ាងសំខាន់ ដើម្បីទទួលបានបទពិសោធន៍ ក្នុងការអភិវឌ្ឍន៍វិស័យ SME ដែលមានជាង៩៩%នៅប្រទេសជប៉ុន ទទួលបានជោគជ័យ ក្នុងការរក្សាចិរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ។

ស្ថិតក្នុងឱកាសនោះ បានប្រកាសផ្សព្វផ្សាយអំពីការចាប់ផ្តើម រៀបចំគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាជាផ្លូវការ អនុវត្តដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងសហការគាំទ្របច្ចេកទេសដោយអង្គការ JICA និងសូមអញ្ជើញសិក្ខាកាមទាំងអស់ ដែលអញ្ជើញមកពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូឯកជន និងដៃគូរអភិវឌ្ឍន៍នានា ចូលរួមវិភាគទានជាមតិយោបល់ និងអនុសាសន៍ ដោយពិនិត្យតាមដានពីរបាយការណ៍បច្ចុប្បន្នភាព និងអនាគត នៃផែនការសកម្មភាព ដែលនឹងត្រូវអនុវត្តជាបន្តបន្ទាប់ ។

បន្ទាប់ពីលោកជំទាវ **ពៅ វរលក្សណ៍** អគ្គនាយិកាសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម អញ្ជើញធ្វើជាវាគ្មិនធ្វើបទបង្ហាញពីសារៈសំខាន់នៃគោលនយោបាយលើកទឹកចិត្ត សហគ្រាសធុនតូច និងមធ្យម និងការចូលរួមផ្តល់គំនិតទស្សនៈ ការសួរ ឆ្លើយ និងអនុសាសន៍នានា ពីសិក្ខាកាមចូលរួមរួចមក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអញ្ជើញ ថ្លែងបិទអង្គសិក្ខាសាលា ដោយបានវាយតម្លៃខ្ពស់ ចំពោះអង្គសិក្ខាសាលាដែលទទួលបានអនុសាសន៍ល្អជាច្រើនសម្រាប់ជាធាតុចូល ក្នុងគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា គំនិត ទស្សនៈដែលឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ទទួលស្វាគមន៍ និង គាំទ្រ នោះរួមមាន៖ លើកទឹកចិត្តការចូលរួមរបស់ស្ត្រី–រៀបចំគោលនយោបាយពន្ធសម្រាប់គាំទ្រ SME –ជម្រុញការចុះបញ្ជី–ស្វ័យប្រកាសសម្រាប់ SME គ្រួសារ–លើកទឹកចិត្តមនុស្សចាស់ និងជនពិការ ក្នុង SME –លើកទឹកចិត្តផ្នែកសារពើភ័ណ្ឌ និងមិនមែនសារពើភ័ណ្ឌ និងពិនិត្យលទ្ធភាពបើកសាលាបង្រៀនផ្នែកចម្លាក់ និងរចនាម៉ូដ ជាដើម ។




SEMINAR
ON
SME PROMOTION POLICY
"Improving Business Enabling Environment,
Strengthening SME Capacity & Competitiveness"
Phnom Penh, 15 July 2014
Co-organized by
JICA
EXIT